# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ៖ធម៌ដែលនាំឲ្យប្រទេសរឹងមាំ

website – www.hoksavann.org



ក្នុងគម្ពីរព្រះត្រៃបិដក ដែលជាគម្ពីរដ៏ធំ របស់ព្រះពុទ្ធសាសនា បានសំដែងអំពីធម៌៧ យ៉ាង ដែលធ្វើឲ្យប្រទេសណាយកទៅអនុវត្ត នឹងធ្វើឲ្យប្រទេសនោះរឹងមាំ មានការលូតលាស់ចំរើន សេចក្ដីវិនាសមិនមានឡើយ ហើយបរទេស មិនអាចចូលមកឈ្លានពានបានឡើយ ។ ធម៌នេះព្រះពុទ្ធសំដែងប្រាប់ពួចំពោះព្រាហ្មណ៍ម្នាក់ឈ្មោះ វស្សការព្រាហ្មណ៍ ដោយមានសេចក្ដីដំណាលថា ព្រះបាទអជាតសត្រូវសោយរាជ្យនៅនគរមគធៈ មា នព្រះបំណងទៅវាយយកដែនវជ្ជី ។ ព្រះបាទអជាតសត្រូវជាពុទ្ធសាសនិកជន គោរពព្រះពុទ្ធយ៉ាងជ្រាលជ្រៅបំផុត ។ មុននឹងព្រះអង្គទៅធ្វើសឹកសង្គ្រាមច្បាំងជាមួយដែនវជ្ជីរបស់ពួកក្សត្រវជ្ជី ព្រះអង្គបានប្រើព្រាហ្មណ៍ម្នាក់ឈ្មោះវស្សការព្រាហ្មណ៍ឲ្យទៅថ្វាយបង្គំព្រះពុទ្ធ ទូលព្រះអង្គអំពីបំណាងរបស់ព្រះអង្គ ។ ព្រះបាទអជាតសត្រូវបានចាត់អាមាត្យព្រះអង្គឲ្យទៅទូលព្រះពុទ្ធនេះដោយមានព្រះបំណងថាបើច្បាំងឈ្នះឬមិនឈ្នះស្ដាប់ព្រះពុទ្ធដីការបស់ព្រះអង្គនឹងបានដឹងការពិតព្រោះព្រះពុទ្ធមិនដែលមានព្រះពុទ្ធដីកាខុសទេ ។ ពេលនោះវស្សការព្រាហ្មណ៍ជាអាមាត្យរបស់ព្រះបាទអជាតសត្រូវបានទៅថ្វាយបង្គំព្រះពុទ្ធ ហើយទូលព្រះពុទ្ធតាមបណ្ដាំរបស់ព្រះរាជាខ្លួន ។ ព្រះពុទ្ធបានជ្រាបអំពីបំណាងនេះហើយ ទើបព្រះអង្គត្រាស់ទៅកាន់ព្រះអានន្ទដែលនៅក្បែរនោះថា ម្នាលអានន្ទ ធម៌៧យ៉ាងដែលតថាគតនឹងពន្យល់តទៅនេះ បើពួកក្សត្រដែនវជ្ជីនៅតែប្រព្រឹត្តតទៅទៀត បរទេសមិនអាចចូលទៅឈ្លានពានបានឡើយ ។ ធម៌៧យ៉ាងនោះគឺ : ១- ពួកក្សត្រដែនវជ្ជីឧស្សាហ៍ប្រជុំគ្នារឿយៗ ដើម្បីពិគ្រោះគ្នារកសេចក្ដីចំរើន និងការពារកុំឲ្យមា

នសេចក្ដីវិនាសរបស់ប្រទេសក្នុងបច្ចុប្បន្ននិងទៅអនាគត ។ ២- ព្រមព្រៀង
គ្នាប្រជុំនិងព្រមព្រៀងគ្នាលើកការប្រជុំ ព្រមទាំងបំពេញការងារតាមមុខងារ
នាទីរបស់ខ្លួនឲ្យបានល្អត្រឹមត្រូវ ។ ៣- មិនបញ្ញត្តបន្ថែមនិងមិនដកច្បាប់ដែ
លពួកក្សត្រមុនៗបានបញ្ញត្តមកហើយ ត្រូវធ្វើតាមច្បាប់ដែលមានមកនោះ
។ ៤- ត្រូវធ្វើសក្ការៈគោរពរាប់អាននិងជឿស្ដាប់ពួកក្សត្រដែនវជ្ជីមានព្រះជ
ន្មច្រើន ដែលមានការពិសោធន៍ក្នុងបញ្ហាស្រុកទេស ។ ៥- ពួកវជ្ជីក្សត្រ មិ
នកំហែងបង្ខំពួកស្ត្រីក្នុងត្រកូល និងពួកកុមារីក្នុងត្រកូលឲ្យទៅរួម ។ ពាក្យ
នេះទំនងជាមិនឲ្យរំលោភស្ត្រី ឬកុមារីនៅក្នុងត្រកូលរបស់ខ្លួន ។ ៦- ធ្វើស
ក្ការៈគោរពរាប់អានបូជាចេតិយ ។ ពាក្យនេះតាមអដ្ឋកថាពោលថា ទីកន្លែង
ទេវតាដែលគេធ្លាប់គោរពបូជា ។ ៧- ម្នាលអានន្ទ ពួកក្សត្រក្នុងដែនវជ្ជីតែង
មានបំណងថា ព្រះអរហន្តទាំងឡាយដែលមិនទាន់មក ក៏សូមមកកាន់ដែន
របស់យើង ព្រះអរហន្តដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅជាសុខក្នុង
ដែនរបស់យើង ។

បន្ទាប់ពីព្រះអង្គមានព្រះពុទ្ធដីកាទៅកាន់ព្រះអានន្ទដូច្នេះហើយ ព្រះអង្គត្រា
ស់ទៅកាន់វស្សការព្រាហ្មណ៍ជាអាមាត្យក្នុងដែនមគធៈថា ម្នាលព្រាហ្មណ៍អ
បរិហានិយធម៌ដែលប្រែថាធម៌មិន សាបសូន្យទាំង៧នេះតាំងនៅក្នុងពួកវជ្ជី
ក្សត្រហើយ បើពួកវជ្ជីក្សត្រនៅតែប្រតិបត្តិធម៌នេះអស់ កាលត្រឹមណា សេច
ក្ដីចំរើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រ សេចក្ដីសាបសូន្យមិនមានឡើយ
អស់កាលត្រឹមណោះ ។ វស្សការព្រាហ្មណ៍ក្រាបទូលព្រះពុទ្ធថា បពិត្រព្រះ
គោតមដ៏ចំរើន ពិតមែនហើយកាលបើក្សត្រដែនវជ្ជីរួបរួមគ្នាកាន់ធម៌ទាំង៧
នេះ ព្រះបាទអជាតសត្រូវក្នុងដែនមគធៈ ជាព្រះរាជារបស់ខ្ញុំព្រះអង្គមិនអាច
អាចចាប់ពួកវជ្ជីក្សត្រដោយការច្បាំងបានទេ វៀរលែងតែការលួងលោមផ្លូវ
ចិត្ត ឬរកមធ្យោបាយធ្វើឲ្យបែកបាក់សាមគ្គីគ្នាធ្វើឲ្យខ្សោយកម្លាំង ទើបប្រទេ
សដទៃចូលទៅឈ្លានពានបាន។

យោលទៅតាមព្រះពុទ្ធដីកាទៅកាន់វស្សការព្រាហ្មណ៍ ដែលចង់ដឹងឱ
វាទរបស់ព្រះអង្គអំពី ការទៅវាយយកប្រទេសក្នុងដែនវជ្ជីរបស់ព្រះបាទអជ
ាតសត្រូវនគរមគធៈបញ្ជាក់ថា ដែនវជ្ជីរបស់ក្សត្រវជ្ជីមានការសាមគ្គីគ្នារឹង
មាំណាស់ សត្រូវមិនអាចចូលមកឈ្លានពានបានឡើយ ជាពិសេសពួក
ក្សត្រវជ្ជីកាន់ធម៌៧យ៉ាង ដូចពោលមកហើយយ៉ាងខ្ជាប់ខ្ជួន ។ គោលសំខា
ន់ក្នុងការអនុវត្តន៍ គឺក្សត្រវជ្ជីបានប្រជុំគ្នាជាញឹកញាប់ជាអចិន្ត្រៃយ៍ ដើម្បីពិ
គ្រោះគ្នាអំពីបញ្ហាជាតិ យកយោបល់ពីចាស់ទុំដែលធ្លាប់មានការពិសោធន៍
មិនបញ្ញត្តច្បាប់បន្ថែមនិងមិនដកច្បាប់ដែលក្សត្រវជ្ជីមុនៗបានបញ្ញត្តហើយ

។ ផ្ទុយទៅវិញ បើក្សត្រវជ្ជីបែកសាមគ្គីគ្នាដោយការញុះញង់ពីខាងក្រៅដែនវជ្ជីនឹងត្រូវវិនាសដោយសត្រូវខាងក្រៅចូលមកលុកលុយ ។ ព្រះបាទអជាតសត្រូវមិនហាន ចូលទៅឈ្លានពានដែនវជ្ជីឡើយ ដោយឃើញកម្លាំងសាមគ្គីរបស់ក្សត្រវជ្ជី និងបានស្ដាប់ព្រះឱវាទរបស់ព្រះពុទ្ធជាម្ចាស់ផង ។

ចំពោះប្រទេសកម្ពុជា បើយើងនាំគ្នាគោរពច្បាប់ គិតប្រយោជន៍ជាតិ មិនប្រើកំហឹងដោយ ពុំមានហេតុផល សាមគ្គីគ្នា សំរេចកិច្ចការជាតិដោយ ការពិគ្រោះគ្នា តុលាការឯករាជ្យប្រកាន់ជំហរយុត្តិធម៌ មិនមានឥទ្ធិពលបរទេសណាដែលមិនស្មោះត្រង់នឹងខ្មែរជាដើម ប្រទេសនេះនឹងមានភាពរឹងមាំ មានស្ថេរភាពនយោបាយ ។អំពើដែលត្រូវជៀសវាង គឺការលួចសម្លាប់គ្នា ការយកតុលាការជាឧបករណ៍ដើម្បីកំចាត់គ្នា ។ បើកឲ្យប្រជាពលរដ្ឋបញ្ចេញយោបល់ដោយ គ្មានការភ័យខ្លាច ។ កំហឹងផ្ទាល់ខ្លួន កុំដឹកនាំឲ្យជាគំនុំជាតិ ។ ត្រូវទទួលពាក្យរិះគន់ក្នុងន័យស្ថាបនា យកមកពិចារណា មិនត្រូវចោទថាបរិហារកេរ្តិ៍ឡើយ ។ ប្រព័ន្ធឃោសនារបស់ជាតិដូចជាវិទ្យុ ទូរទស្សន៍ សារពត៌មានជាដើម ត្រូវប្រកាន់ជំហរអព្យាក្រឹត្យ ផ្សាយឲ្យមានតុល្យភាព ដើម្បីឲ្យប្រជាពលរដ្ឋបានជ្រាបនិងបានយកទៅពិចារណា ។ ប៉ូលិស កងរាជអាវុធហត្ថ កងទ័ពប្រដាប់អាវុធជារបស់ជាតិ សំរាប់បំរើជាតិ មិនមែនសំរាប់គណបក្សណាឡើយ ។៚

❄ ❄

❄